CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២២ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចបន្តផ្តល់ជំនួយដល់អ្នកជួលដែលរងផលប៉ះពាល់ដោយ COVID-19

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ក្រុមប្រឹក្សាក្រុងឡុងប៊ិចបានបោះឆ្នោតជាឯកច្ឆន្ទកាលពីថ្ងៃអង្គារដើម្បីបន្តទៅមុខទៀតនូវបទបញ្ញត្តិគ្រាអាសន្នដែលបញ្ឈប់ការបណ្តេញចេញសម្រាប់អ្នកជួលលំនៅដ្ឋាននិងពាណិជ្ជកម្មមួយចំនួនដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាត COVID-19។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "យើងកំពុងមើលឃើញពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចដែលមិនធ្លាប់មានពីមុនមកចំពោះអ្នកជួលលំនៅដ្ឋាននិងពាណិជ្ជកម្មរបស់យើងនៅឡុងប៊ិចដែលបណ្តាលមកពីជំងឺរាតត្បាតនេះ។ ការពង្រីកបទប្បញ្ញត្តិគ្រាអាសន្ននេះផ្តល់ការធូរស្បើយដល់អ្នកដែលប្រឈមនឹងការបណ្តេញចេញនិងអ្នកដែលនឹងអាចគ្មានផ្ទះសម្បែងក្នុងគ្រាដ៏លំបាកនេះ។"

ការផ្លាស់ប្តូរនេះពន្យារពេលការបណ្តេញចេញនិងពន្យាពេលការបង់ថ្លៃជួលរយៈពេល ៦០ ថ្ងៃបន្ថែមទៀតដល់ថ្ងៃទី ៣១ ខែកក្កដាឆ្នាំ ២០២០។ អ្នកជួលដែលត្រូវបានការពារដោយបទប្បញ្ញត្តិគ្រាអាសន្ននេះនឹងមានរហូតដល់ថ្ងៃទី ៣១ ខែកក្កដាឆ្នាំ ២០២០ ដើម្បីទូទាត់រាល់ថ្លៃជួលដែលបានពន្យារពេលទៅឱ្យម្ចាស់ផ្ទះដោយមិនមានការគិតការប្រាក់និងថ្លៃផ្សេងទៀត។ អ្នកជួលត្រូវបានលើកទឹកចិត្តឱ្យបង្កើតកាលវិភាគទូទាត់ដើម្បីបង់រំលោះថ្លៃជួលដែលត្រូវបានពន្យារពេលក្នុងរយៈពេលដែលបានផ្តល់ឱ្យសង។

ប្រសិនបើអ្នកជួលមិនមានលទ្ធភាពក្នុងការបង់ថ្លៃជួលនៅចន្លោះថ្ងៃទី ៤ ខែមីនាដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០២០ ដោយសារតែការកាត់បន្ថយប្រាក់ចំណូលដែលបណ្តាលមកពី COVID-19 ពួកគាត់ត្រូវតែជូនដំណឹងដល់ម្ចាស់ផ្ទះឱ្យបានដឹងថាពួកគាត់មិនមានលទ្ធភាពបង់ថ្លៃជួលឱ្យទាន់ពេលវេលាទេ។ អ្នកជួលត្រូវផ្តល់ឯកសារអំពីការខាតបង់ប្រាក់ចំណូលដែលបណ្តាលមកពីការបញ្ឈប់ការងារ ពីការចំណាយលើការព្យាបាលចេញពីហោប៉ៅរបស់ខ្លួន ឬពីតម្រូវការឱ្យស្នាក់នៅផ្ទះដោយសារ COVID-19។

រហូតដល់ថ្ងៃទី ៣១ ខែកក្កដាឆ្នាំ ២០២០ ម្ចាស់ផ្ទះដែលចេញលិខិតមិនបង់ប្រាក់ជួលត្រូវតែរួមបញ្ចូលព័ត៌មានអំពីបទប្បញ្ញត្តិបន្ទាន់របស់ក្រុងដើម្បីធានាថាអ្នកជួលបានដឹងពីសិទ្ធិរបស់ពួកគាត់។

ការផ្លាស់ប្តូរនេះមិនអនុវត្តចំពោះអ្នកជួលពាណិជ្ជកម្មធំៗដែលជាក្រុមហ៊ុនពាណិជ្ជកម្មពហុជាតិឬសាធារណៈដែលមានបុគ្គលិក ៥០០ នាក់ឬច្រើនជាងនេះ ក៏ដូចជាអ្នកជួលនៅអាកាសយានដ្ឋានឡុងប៊ិច អ្នកជួលនៅកំពង់ផែ ឬអ្នកជួលនៅតំបន់ទឹកជោរ (Tidelands areas)។ ទីក្រុងឡុងប៊ិចនិងគណៈកម្មការរបស់ក្រុងនឹងធ្វើការជាមួយអ្នកជួលទាំងនេះដោយផ្អែកតាមករណីនីមួយៗដើម្បីដោះស្រាយផលប៉ះពាល់ដែលទាក់ទងនឹង COVID-19 និងចរចាការពន្យាពេលបង់ថ្លៃជួលដែលសមរម្យឬការសម្របសម្រួលផ្សេងទៀត។

បទប្បញ្ញត្តិចុងក្រោយនឹងត្រូវបានពិចារណាដោយក្រុមប្រឹក្សាក្រុងនៅថ្ងៃទី ២៦ ខែឧសភាហើយនឹងត្រូវអនុវត្តភ្លាមៗប្រសិនបើមានការយល់ព្រមពីក្រុមប្រឹក្សាក្រុងនិងចុះហត្ថលេខាដោយអភិបាលក្រុង។

លើសពីនេះក្រុមប្រឹក្សាក្រុងកំពុងស្វែងរកជម្រើសជំនួយផ្សេងៗសម្រាប់ម្ចាស់អចលនៈទ្រព្យដែលត្រូវបានរងផលប៉ះពាល់ដោយ COVID-19 រួមមានការជំនួយដើម្បីជៀសវាងការរឹបអូសទ្រព្យ ជំនួយការសងប្រាក់ពន្ធលើទ្រព្យសម្បត្តិ និងលទ្ធភាពនៃការទទួលមូលនិធិប្រាក់កម្ចីវិល។

ក្រុមប្រឹក្សាក្រុងបានអនុម័តការផ្អាកការបណ្តេញចេញជាបន្ទាន់នៅថ្ងៃទី ២៤ ខែមីនាឆ្នាំ ២០២០ ចំពេលមានការផ្ទុះឡើងនៃជំងឺ COVID-19។

សូមចូលទៅមើលធនធានរបស់ទីក្រុងសម្រាប់ម្ចាស់ផ្ទះ អ្នកជួល និងម្ចាស់ដី។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #